**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ ព្រហស្បតិ៍ ៥ រោច ខែ មាឃ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧*

*រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០២៤*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីកិច្ចពិភាក្សាការងារជាមួយក្រុមប្រឹក្សាធុរកិច្ចសហរដ្ឋអាម៉េរិក-អាស៊ាន
## ( US-ASEAN Business Council — US-ABC )

នារសៀលថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០២៤, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, **ឯកឧត្តមបណ្ឌិត ផាន់ ផល្លា**, រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** បានទទួលជួបពិភាក្សាការងារជាមួយតំណាងក្រុមប្រឹក្សាធុរកិច្ចសហរដ្ឋអាម៉េរិក-អាស៊ាន (US-ABC) ដោយមានការចូលរួមពីតំណាងអគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានគោលនយោបាយ និងអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីពិភាក្សាអំពីកាលានុវត្តភាព ក្នុងការវិនិយោគ និងបរិយាកាសធុរកិច្ចនៅកម្ពុជា ។

តំណាង US-ABC បានធ្វើការវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែង ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ ទាំងផ្នែកធុរកិច្ច ពាណិជ្ជកម្ម និង ការវិនិយោគ រវាងសហរដ្ឋអាម៉េរិក-កម្ពុជា និង បានកោតសរសើរខ្ពស់ចំពោះសមិទ្ធផល របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការជំរុញកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ប្រកបដោយចីរភាព បរិយាប័ន្ន និង ភាពធន់ ។ ក្នុងន័យនេះ, តំណាង US-ABC ដែលមានទាំងក្រុមហ៊ុនដែលកំពុងមានវត្តមាននៅកម្ពុជា ទាំងក្រុមហ៊ុនដែលមានបំណងចាប់ផ្តើមសកម្មភាពនៅកម្ពុជា បានបង្ហាញអំពីគោលបំណង ក្នុងការស្វែងរកកាលានុវត្តភាព ក្នុងការចាប់ផ្តើម និងការពង្រីកការវិនិយោគនៅកម្ពុជា ដើម្បីចាប់យកសក្តានុពលរបស់កម្ពុជា ក៏ដូចជាការចូលរួម ក្នុងការលើកស្ទួយកំណើនសេដ្ឋកិច្ចកម្ពុជា បន្ថែមទៀត ។

ជារួម, តំណាង US-ABC បានស្នើសុំឱ្យមានការពន្យល់អំពីទិដ្ឋភាពធុរកិច្ច និងសក្តានុពលវិនិយោគ ក៏ដូចជាស្នើសុំឱ្យមានការដោះស្រាយបញ្ហាប្រឈមមួយចំនួន ដែលក្រុមហ៊ុនសហរដ្ឋអាម៉េរិកនៅកម្ពុជា បាន និង កំពុងជួបប្រទះ ។ ជាការឆ្លើយតប, **ឯកឧត្តមបណ្ឌិត ផាន់ ផល្លា** ព្រមទាំងតំណាងស្ថាប័នក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានពន្យល់អំពីទិសដៅរបស់រាជរដ្ឋាភិបាល និងបានបំភ្លឺអំពីបញ្ហាប្រឈមនីមួយៗដែលក្រុមហ៊ុនលើកឡើង ។

ជាកិច្ចបញ្ចប់, តំណាង US-ABC បានសម្តែងនូវការថ្លែងអំណរគុណ និងការស្វាគមន៍ចំពោះការបើកកិច្ចពិភាក្សា ដោយបើកចំហ ជាមួយវិស័យឯកជន ដើម្បីដោះស្រាយបញ្ហាជាក់ស្តែង ក្នុងគោលដៅជំរុញការអភិវឌ្ឍវិស័យឯកជន ។ តំណាង US-ABC ក៏បានសម្តែងនូវការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះកម្ពុជា ដោយបន្តចូលរួមកិច្ចពិភាក្សាជាបន្តបន្ទាប់ ដើម្បីផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាល ។ **ឯកឧត្តមបណ្ឌិត ផាន់ ផល្លា** ក៏បានសម្តែងនូវការស្វាគមន៍ ចំពោះការបន្តកិច្ចសន្ទនារវាងធុរជន និងក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ច និង ការវិនិ-យោគ និងស្នើសុំឱ្យតំណាងស្ថាប័នក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រៀបចំកិច្ចពិភាក្សា ដើម្បីស្វែងយល់លម្អិត និង ជួយជំរុញការដោះស្រាយបញ្ហាប្រឈម ដែលក្រុមហ៊ុនសហរដ្ឋអាម៉េរិក ក៏ដូចជាក្រុមហ៊ុនផ្សេងៗទៀត នៅកម្ពុជា ឱ្យបានកាន់តែប្រសើរឡើង ។